**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

នៅថ្ងៃទី ១ ខែ មីនា ឆ្នាំ២០២៣ វេលាម៉ោង ១៤និង១០នាទីរសៀល នៅក្រុមហ៊ុន **ជីនម៉ីយ៉ុង ហ្គាមេនឌីវើឡុបមេន ខូប** ដែលមានទីតាំងនៅភូមិព្រែកតាឡុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ បានបើកកិច្ចប្រជុំពិភាក្សាជាមួយតំណាងកម្មករនិយោជិត ករណីព្យួរការងារកម្មករនិយោជិត ចំនួន ១០៨នាក់ ស្រី៤២នាក់ ដែលកម្មករនិយោជិតសរុបក្នុងក្រុមហ៊ុនចំនួន ១៦២នាក់ ស្រី៧១នាក់ ចាប់ពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០២៣ មូលហេតុដោយសារគ្មានការបញ្ជាទិញ។

ក្រោយពីបានពិភាក្សាគ្នារួចមកភាគីក្រុមហ៊ុនបានឯកភាពជាមួយតំណាងកម្មករដូចខាងក្រោម៖

១. ក្រុមហ៊ុនបានឯកភាពផ្តល់ប្រាក់ឈ្នួលចំនួន ៥០% នៃប្រាក់ឈ្នួលគោល ដល់កម្មករអំឡុងពេលព្យួរការងារ។

២. តំណាងកម្មករបានឯកភាពទទួលយកប្រាក់ឈ្នួលចំនួន ៥០% នៃប្រាក់ឈ្នួលគោល អំឡុងពេលព្យួរការងារ។

៣. ក្រុមហ៊ុននឹងធ្វើការទូទាត់ប្រាក់ឈ្នួលចំនួន ៥០% នេះនៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ២០២៣។

អង្គប្រជុំបានបញ្ចប់នៅម៉ោង ១៦និង ០០នាទីរសៀលនាថ្ងៃខែឆ្នាំដដែលក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់។

ភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០២៣
ហត្ថលេខា និងត្រានាយក
ជ.នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ជីនម៉ីយ៉ុង ហ្គាមេន ឌីវើឡុបមេន ខូប JINMYUNG GARMENT DEVELOPMENT CORP

លី ម៉េង

**តំណាងកម្មករៈ**

- លោកស្រី ព្រុំ ស្រីនាង ........................
- លោក អុំ អាង ........................
- កញ្ញា ចាន់ ម៉ូនីរដ្ឋានី ........................
- លោក គីម ឌី ........................

Scanned with CamScanner